# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្ងាស
# អរិយក្សេត្រ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៩
# ជំនឿរបស់យើងណែនាំឲ្យយើងបង្កើតទំនាក់ទំនង

**អត្ថបទទី១៖ កិច្ចការ ៧,៥៥-៦០**

នៅពេលគេគប់ដុំថ្មសម្លាប់នោះ លោកស្ទេផានទូលអង្វរថា៖ «ព្រះអម្ចាស់យេស៊ូអើយ សូមទទួលវិញ្ញាណរបស់ទូលបង្គំផង!»។ កក ៧,៥៩

**អត្ថបទទី២៖ វិវរណៈ ២២,១២-១៤.១៦-១៧.២០**

សូមឲ្យអស់អ្នកដែលបានឮពោលឡើងដែរថា៖ «សូមព្រះអង្គយាងមក!»។ អ្នកណាស្រេក សុំអញ្ជើញមក! អ្នកណាចង់បាន សុំអញ្ជើញមកទទួលទឹកដែលផ្ដល់ជីវិត ដោយមិនបាច់បង់ថ្លៃ!។ វវ ២២,១៧

**ដំណឹងល្អ៖ យ៉ូហាន ១៧,២០-២៦**

ទូលបង្គំបានសម្ដែងព្រះនាមព្រះអង្គឲ្យគេស្គាល់ ហើយទូលបង្គំនឹងសម្ដែងឲ្យគេរឹតតែស្គាល់ថែមទៀត ដើម្បីឲ្យសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះទូលបង្គំស្ថិតនៅក្នុងគេ ហើយទូលបង្គំក៏ស្ថិតនៅក្នុងគេដែរ។ យហ ១៧,២៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ដែលយើងរំលឹកព្រះយេស៊ូឡើងស្ថានបរមសុខ និងរំលឹកទិវាការផ្សព្វផ្សាយដំណឹងល្អដល់ពិភពលោកទាំងមូល ជាពិសេសជាថ្ងៃដែលប្អូនៗមួយចំនួនទទួលអគ្គសញ្ញាលាបថ្ងាស។ អត្ថបទដែលយើងបានថ្ងៃនេះ ណែនាំឲ្យយើងមើលឃើញរបៀបដែលព្រះយេស៊ូចង់ឲ្យយើងជាគ្រីស្តបរិស័ទ ទៅជាអ្នកប្រកាសដំណឹងល្អ ទៅជាអ្នកផ្សព្វផ្សាយអំពីដំណឹងដ៏ពិសេសដែលព្រះយេស៊ូមានមិនសម្រាប់តែព្រះសហគមន៍របស់យើង គឺសម្រាប់ពិភពលោកទាំងមូល។ សម្រាប់ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក កុំឲ្យព័ត៌មាន ឬអ្វីដែលយើងផ្សព្វផ្សាយគឺសម្រាប់តែកាតូលិកគ្នាយើង តែយើងគិតដល់ប្រទេសកម្ពុជាទាំងមូល។ ពេលយើងប្រកាសអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពេលយើងប្រកាសអំពីព្រះយេស៊ូដែលណែនាំឲ្យយើងទៅជាសញ្ញាសម្គាល់យ៉ាងជាក់ស្ដែង អំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជាប្រចាំថ្ងៃ យើងយល់ថាការប្រកាសរបស់យើងទៅដល់បងប្អូនទាំងអស់នៅលើទឹកដីប្រទេសកម្ពុជា និងពិភពលោកដើម្បីឲ្យគេស្ដាប់ឮ អំពីព្រះសហគមន៍របស់យើង អំពីប្រទេសយើង អំពីជីវិតរបស់យើងជាគ្រីស្តបរិស័ទនៅពេលនេះ។

**តើយើងធ្វើដូចម្ដេច ដើម្បីប្រកាសដំណឹងល្អដល់មនុស្សទាំងអស់? តើយើងធ្វើដូចម្ដេចដើម្បីឲ្យសម្លេងរបស់យើង សក្ខីភាពរបស់យើង ស្នាដៃរបស់យើង ទៅជាសញ្ញាមួយយ៉ាងពិសេស**

**សម្រាប់បងប្អូនឯទៀតៗនៅក្នុងសង្គមបច្ចុប្បន្ននេះ?** អត្ថបទទីមួយ **"បន្តិចទៀតអ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា អ្នករាល់គ្នានិងធ្វើជាបន្ទាល់របស់ខ្ញុំនៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល នៅក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី"**។ មានន័យថា ពីសម័យដើមក្រុមគ្រីស្តទូតមិនទទួលបេសកកម្មមួយចង្អៀតចង្អល់សម្រាប់តែយេរូសាឡឹម ឬអ៊ីស្រាអែលតែប៉ុណ្ណឹង តែសម្រាប់ពិភពលោកទាំងមូលរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី។ ថ្ងៃនេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ទៅប្រទេសរ៉ូម៉ានីជាការធ្វើដំណើរទី៣០របស់ព្រះអង្គក្នុងឋានៈជាសម្តេចប៉ាប។ សម្តេចប៉ាប យាងទៅប្រទេសរ៉ូម៉ានីដើម្បីជួបជាមួយគ្រីស្តបរិស័ទកាតូលិកយើង និងជួបជាមួយនិកាយអរតូដុក ព្រះអង្គមានបំណងចង់ឲ្យកាតូលិកនិងអរតូដុកបន្តធ្វើដំណើរជាមួយគ្នា។ សព្វថ្ងៃ ស្រុកដាច់ស្រយាលនៃផែនដីអស់ហើយ យើងអាចមើលពិភពលោកទាំងមូលតាមរយៈទូរស័ព្ទដៃរបស់យើងបាន។ ថ្ងៃនេះ ព្រះយេស៊ូឲ្យយើងទៅជាសាក្សីបន្ទាល់នៃជីវិតរបស់ព្រះជាម្ចាស់ នេះមាននៅក្នុងលិខិតដែលសម្តេចប៉ាប ដែលបានសរសេរសម្រាប់ទិវាទី៥៣នៃការប្រកាសដំណឹងល្អដល់សង្គមជាតិ។ នៅពេលយើងបានទទួលឫទ្ធានុភាពពីព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងទៅជាសាក្សីផ្ទាល់នៃជំនឿ ជំនឿរបស់យើងណែនាំឲ្យយើងបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ។

សព្វថ្ងៃ យើងអាចបង្កើតទំនាក់ទំនងបានតាមរយៈទូរស័ព្ទដៃរបស់យើង ប៉ុន្តែទំនាក់ទំនងដែលយើងបង្កើតតាមរបៀបផ្សេងៗនេះមិនទាន់ល្អមទេ ជំនឿរបស់យើងណែនាំឲ្យយើងជួបគ្នាផ្ទាល់ ឲ្យយើងមានទំនាក់ទំនងដោយនិយាយជាមួយគ្នាពិតៗ។ ពេលយើងមើលភ្នែកផ្ទាល់ មើលមុខផ្ទាល់ខុសគ្នាឆ្ងាយពីការមើលតាមទូរស័ព្ទដៃ ជំនឿរបស់យើងណែនាំឲ្យយើងបង្កើតទំនាក់ទំនង ប៉ុន្តែជាទំនាក់ទំនងនៅក្នុងការជួបជុំគ្នា។ ឲ្យយើងថែរក្សា ដោយនឹកឃើញដល់ព្រះជាម្ចាស់ដែលជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលយើងទទួលថ្ងៃនេះគឺណែនាំឲ្យព្រះបិតានិងព្រះបុត្រារស់នៅក្នុងសេចក្តីស្រឡាញ់ បង្កើតទំនាងទំនងជាមួយគ្នាទៅវិញទៅមក។ ព្រះជាម្ចាស់របស់យើងមិនមែនព្រះជាម្ចាស់ម្នាក់ឯង ជាព្រះត្រៃឯក មានព្រះបុត្រាគឺព្រះយេស៊ូ មានព្រះបិតា និងមានព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធបង្កើតទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងអញ្ជើញយើងឲ្យយើងចូលនៅក្នុងទំនាក់ទំនងនេះដែរ។ ជាពិសេស តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធដែលជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលបានជម្រុញយើងឲ្យយើងទៅជួបបងប្អូនឯទៀតៗ។

នៅពេលក្រុមគ្រីស្តទូតបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ គេចេញទៅតាមផ្លូវដើម្បីប្រកាសអំពីព្រះយេស៊ូដល់មនុស្សទាំងអស់។ គេបានចេញទៅតាមផ្លូវ គេជួបជាមួយមនុស្សនានាដែល

នៅតាមផ្លូវ ដើម្បីប្រាប់គេថា បងប្អូនអើយ! ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ បងប្អូនអើយ! ព្រះយេស៊ូស្រឡាញ់យើង បងប្អូនអើយ! ព្រះជាម្ចាស់គង់នៅជាមួយយើងអស់កល្បជានិច្ច ...។ នេះជារបៀបដើម្បីបង្កើតទំនាក់ទំនងជាដំបូង ឲ្យយើងបង្កើតទំនាក់ទំនងដោយមើលមុខគ្នាទៅវិញទៅមក ដោយជួបគ្នាផ្ទាល់ ដោយសួរសុខទុក្ខគ្នា។ យើងបង្កើតទំនាក់ទំនងផ្ទាល់មុខ ដើម្បីឲ្យជីវិតរបស់យើងទៅជាកញ្ចក់បង្ហាញអំពីព្រះជាម្ចាស់ដែលជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជាអង្គតែមួយ ដែលណែនាំឲ្យយើងទៅជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលចេះបង្កើតទំនាក់ទំនងយ៉ាងច្បាស់ ក៏ប៉ុន្តែមិនមែនតាមរយៈបណ្តាញសង្គមដែលយើងមាន គឺឲ្យយើងជួបគ្នាផ្ទាល់។ យើងប្រើបណ្តាញផ្សព្វផ្សាយសង្គមដែលយើងមានសព្វថ្ងៃឲ្យបានល្អ ដើម្បីផ្សព្វផ្សាយព័ត៌មាន ដើម្បីចែករំលែកបទពិសោធ ដើម្បីចែករំលែកអំពើល្អដែលយើងបានធ្វើ ឲ្យយើងចូលរួមនៅក្នុងសុខទុក្ខរបស់គេដើម្បីបង្កើតសេចក្តីសង្ឃឹមរួមជាមួយគ្នា។

សម្រាប់យើងដែលជាគ្រីស្តបរិស័ទអ្វីដែលសំខាន់បំផុត គឺនៅពេលយើងជួបជុំគ្នាផ្ទាល់នៅក្នុងអភិបូជា យើងមិនអាចទទួលព្រះកាយព្រះគ្រីស្ត ឬអគ្គសញ្ញាលាបថ្ងាស ឬអគ្គសញ្ញានានាតាមទូរស័ព្ទបានទេ យើងត្រូវការជួបផ្ទាល់ជាមួយព្រះយេស៊ូ នៅក្នុងព្រះកាយព្រះគ្រីស្តនៅពេលយើងថ្វាយអភិបូជា។ ដូច្នេះ សម្រាប់យើងជាគ្រីស្តបរិស័ទនៅពេលយើងចូលអភិបូជា នៅពេលយើងជួបជាមួយបងប្អូនឯទៀតៗយើងបង្កើតទំនាក់ទំនងនៅក្នុងសេចក្តីស្រឡាញ់។ ឲ្យយើងប្រកាស "**អាម៉ែន**" មានន័យថាខ្ញុំជាសាវ័ករបស់ព្រះគ្រីស្ត ខ្ញុំជឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ខ្ញុំផ្ញើជីវិតរបស់ខ្ញុំទាំងស្រុងទៅលើព្រះជាម្ចាស់។ អាម៉ែនពិតមែនព្រះយេស៊ូគង់នៅ អាម៉ែនពិតមែនខ្ញុំចង់ធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ អាម៉ែនខ្ញុំជាគ្រីស្តបរិស័ទដែលស្រឡាញ់ព្រះជាម្ចាស់ ដែលស្រឡាញ់បងប្អូនឯទៀតៗ។ អាម៉ែន៕